00366762

D158/5/3/15

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ

Pre-Trial Chamber
Chambre Préliminaire

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ២០)

ចំពោះមុខ:
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 08 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Luy

សាធារណៈ:

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់
សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរ
លើកទីដប់មួយ របស់ នួន ជា**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
Pierre Olivier SUR
Elizabeth RABESANDRATANA
Olivier BAHOUGNE
David BLACKMAN
Annie DELAHAIE

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michiel G. KARNAVAS

00366763



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" បានទទួល "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរអំពីការចោទប្រកាន់ជាហូរហែអំពីអំពើពុករលួយ" និង "សំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ឲ្យឆាប់រហ័ស" ដែលដាក់ដោយសហមេធាវីការពារក្តី អៀង សារី ("ជនត្រូវចោទ") នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍")[១]។

## I. សាវតានីតិវិធី

១. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ សហមេធាវីការពារក្តី នួន ជា បានដាក់ "សំណើលើកទីដប់មួយ សុំបើកកិច្ចស៊ើបសួរ" ("សំណើលើកទីដប់មួយ")[២] ចំពោះមុខសហចៅក្រមស៊ើបអង្កេត ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ លើការចោទប្រកាន់អំពីអំពើពុករលួយនៅ អ.វ.ត.ក[៣]។

២. នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ សហមេធាវីការពារជនត្រូវចោទបានដាក់ "ញត្តិរបស់អៀង សារី សុំចូលរួម និងទទួលយកតាម "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទី១១ របស់ នួន ជា" ("ពាក្យសុំរបស់ អៀង សារី សុំចូលរួមសំណើសុំទី១១")[៤]។

៣. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចលើសំណើសុំ [លើកទី១១ របស់ នួន ជា] ស្នើសុំបំពេញកិច្ចស៊ើបសួរ" ("ដីកាសម្រេច") ដោយបានឃើញពាក្យសុំ ដែលដាក់ដោយក្រុមមេធាវីការពារក្តីជនត្រូវចោទ អៀង សារី។ នៅក្នុងដីកាសម្រេចរបស់

---

[១] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបំពេញកិច្ចស៊ើបសួរអំពីការចោទប្រកាន់ជាហូរហែអំពីអំពើពុករលួយ និងសំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់ឲ្យឆាប់រហ័ស, ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, D158/5/3/1 ("បណ្តឹងឧទ្ធរណ៍")។

[២] សំណើសុំលើកទី១១ ស្នើសុំបើកកិច្ចស៊ើបសួរ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, D158 ("សំណើសុំលើកទី១១")។

[៣] សំណើសុំលើកទី១១, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, D158 កថាខណ្ឌ១៧។

[៤] ពាក្យសុំរបស់ អៀង សារី សុំចូលរួម និងទទួលយកតាមសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី១១ របស់ នួន ជា, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, D158/2។

00366764



ខ្លួន សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ខ្លួនពុំមានយុត្តាធិការចាំបាច់ ក្នុងការបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំនោះឡើយ ហើយថា សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើករណីរដ្ឋបាល គឺជា "រឿងមិនចាំបាច់"[៥]។

៤. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ដីកាសម្រេចនេះ ត្រូវបានជូនដំណឹងដល់ជនត្រូវចោទ។

៥. នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ សហមេធាវីជាតិរបស់ជនត្រូវចោទ បានជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច និងនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីការពារក្ដី បានដាក់បណ្ដឹងឧទ្ធរណ៍។

៦. នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ពាក្យសុំស្ដីពីការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍[៦]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីការពារក្ដីជនត្រូវចោទ បានដាក់ចម្លើយតបរបស់ខ្លួនតបទៅនឹងពាក្យសុំរបស់សហព្រះរាជអាជ្ញា ដោយស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធពាក្យសុំស្ដីពីការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់របស់សហព្រះរាជអាជ្ញា[៧]។

៧. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ ("សារណាតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី")[៨]។ នៅថ្ងៃទី២១ ខែ

---

[៥] សហចៅក្រមស៊ើបអង្កេត "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ នួន ជា", ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, D158/5 កថាខណ្ឌ១០, ១៣ ("ដីកាសម្រេច") ។

[៦] ពាក្យសុំរបស់សហព្រះរាជអាជ្ញាស្ដីពីការបន្ថែមចំនួនទំព័រ និងពន្យារពេលវេលាកំណត់ ដើម្បីដាក់ចម្លើយតបរួមរបស់ខ្លួន ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីអំពើពុករលួយ, ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៩, D158/5/3/2។

[៧] ចម្លើយតបទៅនឹងពាក្យសុំរបស់សហព្រះរាជអាជ្ញា សុំឱ្យបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ ដើម្បីដាក់ឯកសារសេចក្ដីឆ្លើយតបរួមគ្នាទៅនឹងបណ្ដឹងឧទ្ធរណ៍នានា ប្រឆាំងនឹងដីកាសម្រេចស្ដីពីអំពើពុករលួយ, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩, D158/3/3។

[៨] សារណាតបរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ស្ដីអំពីបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា, អៀង សារី, ខៀវ សំផន និងអៀង ធីរិទ្ធ ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីសំណើលើកទី១១ ស្នើសុំឱ្យមានកិច្ចស៊ើបសួរ, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩, D158/5/3/10 ("សារណាតបរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី")។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ឧសភា ឆ្នាំ២០០៩ ដោយបានឃើញសំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំពន្យារពេលកំណត់ដើម្បីដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍[៩] អង្គបុរេជំនុំជម្រះបានទទួលយកសារណាតបរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានដាក់យឺតពេលកំណត់ អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង និងមាត្រា៩ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ[១០]។

៨. នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានបដិសេធពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យបន្ថែមទំព័រ ប៉ុន្ដែទទួលយកសំណើសុំពន្យារពេលវេលាកំណត់ ដើម្បីដាក់ចម្លើយតបដោយពន្យារពេលវេលាកំណត់រហូតដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩[១១]។

៩. សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩[១២]។

១០. នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះ បានចេញសេចក្ដីបង្គាប់ដល់សហមេធាវីការពារក្ដីជនត្រូវចោទ ដោយបង្គាប់ឱ្យសហមេធាវីការពារក្ដីដាក់សារណាតបទៅនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍[១៣]។

---

[៩] សំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សុំពន្យារពេលកំណត់ក្នុងការដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដីប្រឆាំងនឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ស្ដីពីអំពើពុករលួយ, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩, D158/5/3/5។

[១០] សេចក្ដីសម្រេចស្ដីពីការទទួលយកការដាក់សារណាតបយឺត របស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩, D158/5/3/7។

[១១] សេចក្ដីសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យបន្ថែមទំព័រ និងពេលវេលាកំណត់ដើម្បីដាក់ឯកសារសេចក្ដីឆ្លើយតបរួមគ្នារបស់ខ្លួន ទៅនឹងបណ្ដឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាសម្រេចស្ដីពីអំពើពុករលួយ, ថ្ងៃ២២ ខែឧសភា ឆ្នាំ២០០៩, D158/5/3/9។

[១២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដីប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើសុំឱ្យមានកិច្ចស៊ើបសួរទាក់ទិននឹងការចោទប្រកាន់អំពីអំពើពុករលួយ, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩, D158/5/3/11 ("ចម្លើយតបរួម")។

[១៣] សេចក្ដីបង្គាប់ដល់សហមេធាវីការពារក្ដីជនត្រូវចោទពាក់ព័ន្ធនឹង "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី ប្រឆាំងនឹងដីកាសម្រេចបដិសេធរបស់សហចៅក្រមស៊ើបអង្កេតទៅនឹង[illegible]

១១. សហមេធាវីការពារក្តីជនត្រូវចោទ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨[16]។

១២. នៅពេលទទួលបានការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿង ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ។ ដើម្បីធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះបានពិនិត្យមើលឯកសារនានានៅក្នុងសំណុំរឿង និងភស្តុតាងទាំងអស់ ដែលបានដាក់បន្ថែម រហូតមកទល់ពេលដែលសហមេធាវីការពារក្តីជនត្រូវចោទបានដាក់ការឆ្លើយតប តាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ដែលជាថ្ងៃចុងក្រោយអនុញ្ញាត្តិឱ្យភាគីនានាផ្តល់មតិយោបល់ផ្សេងៗ ឬដាក់ភស្តុតាង ដើម្បីបានជាប្រយោជន៍សម្រាប់ខ្លួន។

## II. ច្បាប់ពាក់ព័ន្ធ

១៣. សេចក្តីសំអាងបានយោងលើមាត្រា២១(១), មាត្រា ៣៥, មាត្រា៥៥(១០), មាត្រា៥៨(៦), មាត្រា៧៣, និងមាត្រា៧៤(៣)(ខ)។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១៤. នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើសំណើលើកទីដប់មួយ ដោយបានឃើញពាក្យសុំដែលដាក់ដោយក្រុមមេធាវីការពារក្តីជនត្រូវចោទ អៀង សារី។ ដីកាសម្រេចបានជូនដំណឹងដល់ជនត្រូវចោទនៅថ្ងៃដដែល។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ សហមេធាវីការពារជនត្រូវចោទ បានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍

---

កិច្ចស៊ើបសួរទាក់ទិននឹងការចោទប្រកាន់អំពើពុករលួយ" ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨, D158/5/3/12 ("សេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ")។

[16] ចម្លើយតបទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ទាក់ទងនឹងភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, D158/5/3/13។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ត្រូវបានដាក់នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ នៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

១៥. សហមេធាវីការពារក្តីជនត្រូវចោទបានដាក់បណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង[១៥]។ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីជនត្រូវចោទបានលើកឡើងថា៖

> "បណ្តឹងឧទ្ធរណ៍នៅតែអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ខ) ទោះបីជាសហចៅក្រមស៊ើបអង្កេតបានប្រកាសថា "ខ្លួនពុំមានយុត្តាធិការក្នុងការបំពេញកិច្ចស៊ើបសួរដូចដែលបានស្នើសុំ" ជាជាងសម្រេចសេចក្តីទៅលើខ្លឹមសារនៃសំណើសុំ។ ចំពោះការផ្តល់សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ដែលបានបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនោះ វិធាន ៧៤(៣)(ខ) មិនបានបែងចែកថាតើសំណើសុំនេះ ត្រូវបានបដិសេធដោយសារតែខ្លឹមសារ ឬបដិសេធដោយសារតែភាពខ្វះយុត្តាធិការនោះទេ។ ការពិតដែលសំណើសុំនោះត្រូវបានបដិសេធ គឺជាកត្តាដែលបានលេចចេញតែមួយគត់ដែលត្រូវយកទៅធ្វើការពិចារណា ហើយដែលបានផ្តល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នោះ"។

១៦. សហមេធាវីការពារក្តីជនត្រូវចោទតវ៉ាថា ព័ត៌មានដែលស្នើសុំសហចៅក្រមស៊ើបអង្កេតតាមរយៈសំណើសុំលើកទីដប់មួយ ស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេត ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងថា សហចៅក្រមស៊ើបអង្កេតមានអំណាចជាប់មកជាមួយ និងភារកិច្ចធ្វើឱ្យមានភាពយុត្តិធម៌នៃដំណើរការនីតិវិធីរបស់តុលាការ[១៦]។ សហមេធាវីការពារក្តីបានលើកឡើងថា វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតដឹកនាំកិច្ចស៊ើបសួរដោយឥតលម្អៀង និងថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចក្នុងការស្វែងរក ឬបង្ហាញភស្តុតាងដាក់បន្ទុកឬដោះបន្ទុកជូនដល់ភាគីនានា[១៧]។ សហមេធាវីការពារក្តីបានលើកឡើងថា ទោះបីជាសហចៅក្រមស៊ើបអង្កេតមានដែនកំណត់ ក្នុងការស៊ើបសួរត្រឹមតែអង្គហេតុនានា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តាមវិធាន ៥៥(២) និងមាត្រា២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្តី ក៏បទប្បញ្ញត្តិទាំងនេះ អាចមិនត្រូវយកធ្វើជាសំអាងដោយសហចៅក្រមស៊ើប

---

[១៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៥-៧។

[១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៣។

[១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៦-១៧។



E.C.C.C * C.E.T.C
TRIAL CHAMBER CHAMBRE PRÉLIMINAIRE

អង្កេត ឬសហព្រះរាជអាជ្ញា ដើម្បីដាក់កម្រិតនូវវិសាលភាពពេលវេលានៃអង្គហេតុនានា ដែលអាចជាប់ពាក់ព័ន្ធដល់ការលាតត្រដាងបង្ហាញការពិត ចំពោះឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[១៨]។ នៅក្នុងបរិបទនេះ សហមេធាវីការពារក្ដីសន្និដ្ឋានថា សំណើសុំលើកទី១១ គឺមិនមែនជា "បញ្ហាថ្មីសន្ធាងចំពោះអង្គហេតុ ដែលគ្របដណ្ដប់លើកិច្ចស៊ើបសួររបស់តុលាការបច្ចុប្បន្ននេះទេ"[១៩]។

១៧. យោងតាមទម្រង់នៃបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាមិនបានដេញដោលលើភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នោះទេ នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍[២០]។

១៨. សហព្រះរាជអាជ្ញាបានសន្និដ្ឋាននៅក្នុងចម្លើយតបរបស់ខ្លួនថា អនុលោមតាមវិធានផ្ទៃក្នុង សំណើលើកទីដប់មួយមិនស្ថិតនៅក្រោមយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតឡើយ[២១] ហើយការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះក៏មិនបានបង្ហាញឱ្យឃើញផងដែរ[២២]។ សហព្រះរាជអាជ្ញាក៏បានតវ៉ាផងដែរថា សំណើលើកទីដប់មួយក៏មិនស្ថិតនៅក្រោមយុត្តាធិការដែលមានជាប់មកជាមួយ (inherent jurisdiction) របស់តុលាការនេះដែរ[២៣]។

១៩. នៅក្នុងចម្លើយតបរបស់ខ្លួន ទៅនឹងសេចក្ដីបង្គាប់របស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី១៦ មិថុនា ឆ្នាំ២០០៩ សហមេធាវីការពារក្ដីជនត្រូវចោទបានលើកឡើងថា៖

> "យុត្តាធិការរបស់ [សហចៅក្រមស៊ើបអង្កេត] ទាក់ទងនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ គឺជាបញ្ហាស្មុគស្មាញមួយដែលទាក់ទងនឹងបញ្ហាស្នូលនៃបណ្ដឹងឧទ្ធរណ៍ ដែលបញ្ហានោះគឺការជះឥទ្ធិពលនៃអំពើពុករលួយរបស់តុលាការ និងផ្នែករដ្ឋបាលមកលើភាពត្រឹមត្រូវនៃកិច្ចដំណើរការ

---

[១៨] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១៨។
[១៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២១។
[២០] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៤។
[២១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥៤-៥៧។
[២២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦០ និង៦១។
[២៣] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦២-៦៤។

នីតិវិធី។ [...] ប៉ុន្តែបញ្ហានេះនឹងមិនមានឥទ្ធិពលអ្វីមកលើភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះឡើយ ហើយដាច់ខាតមិនត្រូវយល់ខុសពីបញ្ហានេះឡើយ”[២៤]។

២០. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ខ្លួនគាំទ្រយ៉ាងពេញទំហឹងចំពោះសំណើលើកទឹកដប់មួយរបស់សហមេធាវីការពារក្តីជនត្រូវចោទ “សុំឱ្យ អ.វ.ត.ក ស៊ើបអង្កេតបន្ថែមទៀតលើអំពើពុករលួយ” ហើយ “អ.វ.ត.ក ជាពិសេសសហចៅក្រមស៊ើបអង្កេត មានសមត្ថកិច្ចបើកកិច្ចស៊ើបសួរលើបញ្ហានេះ[២៥]”។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតវ៉ាថា “ដោយសារតែ អ.វ.ត.ក ដំណើរការទៅដោយផ្អែកទៅលើភាពមិនលំអៀង និងឯករាជ្យភាពនៃតុលាការ [...] ការដោះស្រាយលើបញ្ហានេះស្ថិតនៅក្នុងវិសាលភាពរបស់ អ.វ.ត.ក មិនថាបញ្ហានេះ មានភាពអាម៉ាស់យ៉ាងណាក៏ដោយ”[២៦]។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមទៀតថា “វាមានមន្ទិលសង្ស័យតិចប៉ុណ្ណោះដែលថាការស៊ើបអង្កេតលើកករណីនេះ ស្ថិតនៅក្នុងវិសាលភាពនៃវិធាន៣៥ នៃវិធានផ្ទៃក្នុង ឬយ៉ាងណា”[២៧] ហើយអំណាចជាប់មកជាមួយនេះទាមទារឱ្យសាលាក្តីទាំងឡាយ ដោះស្រាយទង្វើជ្រៀតជ្រែកដល់កិច្ចការរដ្ឋបាល[របស់ខ្លួន]”[២៨]។ យោងតាមសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អំណាចជាប់មកជាមួយនេះ “រួមជាមួយនឹងអំណាចដូចមានចែងនៅក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង បង្កើតបានជាយុត្តាធិការសម្រាប់ អ.វ.ត.ក ក្នុងការដោះស្រាយបញ្ហាអំពើពុករលួយ និងក្នុងការបើកកិច្ចស៊ើបសួរបន្ថែមលើករណីនេះ”[២៩]។

## ការពិចារណារបស់អង្គបុរេជំនុំជម្រះ

២១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា អនុលោមតាមវិធាន៧៣ នៃវិធានផ្ទៃក្នុង ខ្លួនមានយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ ដែលបានប្តឹងប្រឆាំងនឹងប្រភេទនៃសេចក្តីសម្រេចមួយចំនួនរបស់សហចៅក្រម

[២៤] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩, កថាខណ្ឌ៣។
[២៥] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៤។
[២៦] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ៥-១០។
[២៧] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១១។
[២៨] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៣។
[២៩] សារណាតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១៤។

ស៊ើបអង្កេត "ដូចមានចែងនៅក្នុងវិធាន៧៤ នៃវិធានផ្ទៃក្នុង"។ វិធាន៧៤(៣)(ខ) ផ្តល់ឱ្យជនត្រូវចោទនូវសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេតដែលបានបដិសេធ "ពាក្យសុំបើកកិច្ចស៊ើបសួរទាំងឡាយ ដែលបានអនុញ្ញាតក្រោមវិធានផ្ទៃក្នុងនេះ"។ នៅពេលយើងយកឃ្លា "ដូចមានចែងនៅក្នុងវិធាន៧៤ នៃវិធានផ្ទៃក្នុង" នៅក្នុងវិធាន៧៣(ក) នៃវិធានផ្ទៃក្នុង មកអានរួមជាមួយនឹងបទប្បញ្ញត្តិវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង វាបានបង្ហាញថា ដើម្បីអាចអនុវត្តវិធាន៧៣(ក) នៃវិធានផ្ទៃក្នុងបាន បុរេលក្ខខណ្ឌចំនួនពីរត្រូវតែបំពេញ។ បុរេលក្ខខណ្ឌទីមួយគឺ ត្រូវមានសំណើសុំ "ដែលអនុញ្ញាតដោយវិធានផ្ទៃក្នុង" និងបុរេលក្ខខណ្ឌទីពីរគឺ សំណើសុំនោះត្រូវតែបាន "បដិសេធ" ដោយសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះនៅក្នុងករណីមួយនេះ បញ្ហាចម្បងនៃភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះ គឺថាតើសំណើលើកទីដប់មួយស្នើសុំបើកកិច្ចស៊ើបសួរ "ត្រូវបានអនុញ្ញាតតាមវិធានផ្ទៃក្នុង" ដែរឬទេ។

២២. សំណើលើកទីដប់មួយ ដែលស្នើសុំដោយសហមេធាវីការពារក្តីជនត្រូវចោទ គឺចង់បានព័ត៌មានដែលអាចបង្ហាញពី "អំពើពុករលួយនៅក្នុងស្ថាប័ន" របស់អ.វ.ត.ក។ សំណើលើកទីដប់មួយ នេះផ្អែកលើមូលដ្ឋានច្បាប់មួយចំនួន ក្នុងនោះរួមមានវិធាន២១(១) វិធាន៥៥(១០) និងវិធាន៥៨(៦)នៃវិធានផ្ទៃក្នុង។

២៣. នៅក្នុងបណ្តឹងឧទ្ធរណ៍ និងសារណាតបរបស់ខ្លួនតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ សហមេធាវីការពារក្តីជនត្រូវចោទមិនបានផ្តល់ការពន្យល់គ្រប់គ្រាន់ថាតើសំណើសុំព័ត៌មានចំពោះការចោទប្រកាន់ អាចត្រូវគ្នាយ៉ាងដូចម្តេចទៅនឹងអត្ថន័យនៃវិធានច្បាប់ "ពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង" ដូចមានចែងនៅក្នុងវិធាន៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។

២៤. យោងតាមវិធានផ្ទៃក្នុង សំណើសុំបើកកិច្ចស៊ើបសួរដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង រួមមានសំណើដែលដាក់ជូនទៅសហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន៥៥(១០) និងវិធាន៥៨(៦)នៃវិធានផ្ទៃក្នុង។ សំណើលើកទីដប់មួយបានអះអាងថា បានផ្អែកលើសម្អាងផ្លូវច្បាប់ទាំងនេះ។ ដូច្នេះនៅពេលពិនិត្យតាមរបៀបនេះ វាហាក់ដូចជាសំណើលើកទីដប់មួយស្ថិតក្នុងប្រភេទនៃសំណើសុំ "ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង"។ ប៉ុន្តែ ផ្ទុយពីការអះអាងទាំងនេះរបស់ជនត្រូវចោទ អង្គបុរេ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

ជំនុំជម្រះយល់ឃើញថា អង្គហេតុដែលជនត្រូវចោទស្នើសុំឱ្យដោះស្រាយតាមរយៈការដាក់សំណើលើកទីដប់មួយ មិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុងនោះទេ។ អង្គហេតុដែលជនត្រូវចោទបានចោទប្រកាន់ ហើយស្នើសុំឱ្យដោះស្រាយគឺអង្គហេតុមួយដែលអាចបង្ហាញអំពី "ការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ឬ "អំពើពុករលួយ" នៅក្នុង អ.វ.ត.ក។ វិធាន៥៥(១០) និងវិធាន៥៨(៦) ត្រូវយកមកអានឱ្យស្របគ្នាជាមួយនឹងអនុវិធាន១ នៃវិធាន ៥៥(១) នៃវិធានផ្ទៃក្នុង ដែលចែងដូចតទៅ៖

> "ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

២៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា យុត្តាធិការរបស់ អ.វ.ត.ក កើតចេញពីកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[៣០] ដែលជាលិខិតុបករណ៍បង្កើតស្ថាប័ន អ.វ.ត.ក។ លិខិតុបករណ៍ទាំងនេះ សំដៅទៅលើតែ "ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" តែប៉ុណ្ណោះ។ ពុំមានឧបញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀង ឬច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងយោងអំពី "អំពើនានា" ដែលជា "ការជ្រៀតជ្រៀកនៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ឬ "អំពើពុករលួយ" ដូចដែលបានលើកឡើងនោះទេ។

២៦. នៅក្នុងបរិបទនេះ សំណើលើកទីដប់មួយលើកឡើងលាយឡំគ្នាមិនត្រឹមត្រូវរវាងអង្គហេតុដែលបានចោទប្រកាន់ និងបទប្បញ្ញត្តិច្បាប់ ដែលសហមេធាវីការពារក្តីជនត្រូវចោទ បានយកមកផ្អែកដើម្បីបង្កើតជាយុត្តាធិការសម្រាប់សំណើរបស់ខ្លួន។ វិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុង មិនអាចយកមកប្រើប្រាស់ជាមូលដ្ឋានច្បាប់ សម្រាប់ដាក់សំណើសុំបើកកិច្ចស៊ើបអង្កេតចំពោះអង្គហេតុ ដែលអាចបង្ហាញពីការជ្រៀតជ្រៀកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬអំពើពុករលួយ

[៣០] សូមអានមាត្រា២(១) និងមាត្រា៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ "កិច្ចព្រមព្រៀង" ដូចដែលមានចែងស្របគ្នាជាមួយមាត្រា៣, ៤, ៥, ៦, ៧ និង៨ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

នៅក្នុងអ.វ.ត.ក ឡើយ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើលើកទីដប់មួយពុំស្ថិតនៅក្នុងប្រភេទនៃ "សំណើសុំឱ្យមានកិច្ចស៊ើបសួរណាមួយ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុងទេ" នោះទេ។

២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា "អំពើនានា" ដែលជា "ការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" មានចែងនៅក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង។ អនុលោមតាមបុព្វកថានៃវិធានផ្ទៃក្នុង គោលបំណងនៃវិធានផ្ទៃក្នុង មិនមែនដើម្បីកំណត់នូវអំណាចរបស់ អ.វ.ត.ក ទេ។ ប៉ុន្តែវិធានផ្ទៃក្នុងមានគោលបំណង៖

> "ប្រមូលនូវនីតិវិធីជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់អនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និង[...] អនុម័តវិធានមួយចំនួនបន្ថែមទៀត នៅពេលណាដែលច្បាប់កម្ពុជាជាធរមាន ពុំអាចដោះស្រាយបានចំពោះករណីពិសេសណាមួយ"។

២៨. វិធាន៣៥ នៃវិធានផ្ទៃក្នុងចែងថា អ.វ.ត.ក "អាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច" នូវជនណាម្នាក់ដែល "ជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"។ វិធាននេះបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយ "បញ្ហាពិសេស" ដូចមានចែងនៅក្នុងបុព្វកថានៃវិធានផ្ទៃក្នុង ដើម្បីការពារនីតិវិធីចំពោះមុខ អ.វ.ត.ក ពីសកម្មភាពមិនសមរម្យ ដែលអាចបង្កើតភាពអយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធី។ វិធាន៣៥ នៃវិធានផ្ទៃក្នុង ពុំបានបង្កើតយុត្តាធិការចម្បងបន្ថែមសម្រាប់ អ.វ.ត.ក ឡើយ ដែលចំណុចនេះវាហួសពីវិសាលភាពនៃវិធានផ្ទៃក្នុង យ៉ាងច្បាស់។ អំណាចដែលផ្តល់ឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដើម្បីដោះស្រាយនូវអំពើនានាដែលអាចជា "ការជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" បង្ហាញយ៉ាងច្បាស់ថា វាជាទម្រង់នៃយុត្តាធិការបន្ទាប់បន្សំសម្រាប់ អ.វ.ត.ក តែប៉ុណ្ណោះ។ យុត្តាធិការនេះពុំពាក់ព័ន្ធទៅនឹងយុត្តាធិការ ដូចមានចែងនៅក្នុងវិធាន៥៥(១០) និងវិធាន៥៨(៦) នៃវិធានផ្ទៃក្នុងនោះទេ។

២៩. ចំពោះវិធាន៣៥ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងនេះមិនមានចែងអំពីការផ្តួចផ្តើមបើកកិច្ចស៊ើបសួរតាមសំណើរបស់ភាគីណាមួយនោះទេ។ ប៉ុន្តែវិធានផ្ទៃក្នុងបានផ្តល់ឆន្ទានុសិទ្ធិដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។ ហេតុដូច្នេះ វិធាន៣៥ នៃ

វិធានផ្ទៃក្នុងមិនអាចផ្តល់មូលដ្ឋានអនុញ្ញាត្តិឱ្យភាគីស្នើសុំបើកកិច្ចស៊ើបសួរ ហើយបើកឱ្យប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា ករណីនេះកំពុងស្ថិតនៅចំពោះមុខស្ថាប័នសមស្របគឺ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។

៣០. អង្គបុរេជំនុំជម្រះយល់ឃើញបន្ថែមថា សហមេធាវីការពារក្តីបានលើកឡើងអំពីការព្រួយបារម្ភថាតើអត្ថិភាពនៃអំពើពុករលួយ បានជះឥទ្ធិពលដល់សេចក្តីសន្និដ្ឋានលើអង្គហេតុដែលបានធ្វើ ឬដែលនឹងត្រូវធ្វើដោយសហចៅក្រមស៊ើបអង្កេតក្នុងការវាយតម្លៃភស្តុតាងដែលប្រមូលបាន ឬពិនិត្យទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ នៅក្នុងបរិបទនេះ សហមេធាវីការពារក្តីលើកទឡ្ហីករណ៍ថា ប្រសិនបើរកឃើញថាមានភស្តុតាងទាក់ទិននឹងអំពើពុករលួយ ភស្តុតាងនេះជាភស្តុតាងដោះបន្ទុក និងថា វិធាន៥៥(៥) នៃវិធានផ្ទៃក្នុង ណែនាំឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរឥតលម្អៀង និងថា សហចៅក្រមស៊ើបអង្កេតមានភារកិច្ចស្រាវជ្រាវ និងបង្ហាញភស្តុតាងដោះបន្ទុកនិងដាក់បន្ទុកដល់ភាគីនានា។ ចំពោះការអះអាងទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំលើកទីដប់មួយ មិនបានផ្អែកលើវិធាន៥៥(៥) នៃវិធានផ្ទៃក្នុងទេ ហើយលោក អៀង សារីគ្រាន់តែប្រើប្រាស់ “ទឡ្ហីករណ៍អង្គហេតុ និងអង្គច្បាប់ទាំងអស់” ដែលមានចែងនៅក្នុងសំណើសុំលើកទីដប់មួយ ដោយមិនមានបន្ថែមវិធាន៥៥(៥) នៃវិធានផ្ទៃក្នុង ជាមូលហេតុនៃសំណើសុំ ដែលសំណើសុំនេះអាចនឹងសម្រេចតាមរយៈសំណើសុំផ្សេងៗទៀត។ បញ្ហាដែលលើកឡើងនេះស្ថិតនៅខាងក្រៅដែនកំណត់របស់បណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ ហេតុដូច្នេះ បញ្ហានេះនឹងមិនធ្វើការពិចារណាបន្ថែមទៀតទេ[៣១]។

## <u>សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង</u>

៣១. សហមេធាវីការពារក្តីបានលើកឡើងថា ភស្តុតាងនៃអំពើពុករលួយនៅ អ.វ.ត.ក អាចនឹងប៉ះពាល់ដល់ភាពយុត្តិធម៌ និងភាពឥតលម្អៀងរបស់តុលាការ[៣២] និងលើកឡើងថា៖

---

[៣១] ពាក្យសុំរបស់ អៀង សារី ដើម្បីចូលរួមលើសំណើលើកទី១១ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, D158/2។

[៣២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤១-៤៣។

"ប្រសិនជាបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី ត្រូវបានប្រកាសថា មិនអាចទទួលយកបាន អង្គបុរេជំនុំជម្រះ ប្រាកដជារាំងផ្លូវជនត្រូវចោទនានាមិនឱ្យស្វែងរកថា តើភាពត្រឹមត្រូវនៃដំណើរការតុលាការទាំងមូលមានជាប់ប្រទ្បាប់ប្រទ្បូកដែរឬទេ។ ការសន្និដ្ឋានបែបនេះ គឺផ្ទុយនឹងយុត្តិធម៌តាម "និយាមអន្តរជាតិ" ដែលមានចែងនៅក្នុងបុព្វកថានៃវិធានផ្ទៃក្នុង"[៣៣]។

៣២. ទាក់ទិនទៅនឹងបញ្ហាទាំងនេះដែលសហមេធាវីការពារក្ដីបានលើកឡើង, វិធាន២១ នៃវិធានផ្ទៃក្នុងចែងថា៖

"១. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមានត្រូវតែបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ [...]"។

៣៣. អង្គបុរេជំនុំជម្រះនឹងពិនិត្យថា តើវិធាន២១នៃវិធានផ្ទៃក្នុង តម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើការបកស្រាយតាមន័យទូលាយចំពោះសិទ្ធិប្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទដែរឬទេ ដើម្បីធ្វើយ៉ាងណាការពារផលប្រយោជន៍របស់ជនត្រូវចោទចំពោះនីយ័តភាព តម្លាភាព និងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី។

---

[៣៣] ចម្លើយតបរបស់សហមេធាវីការពារក្ដីតបទៅនឹងសេចក្ដីបង្គាប់របស់អង្គបុរេជំនុំជម្រះចុះថ្ងៃ១៦ មិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ៥។

៣៤. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធានផ្ទៃក្នុងបើកឱ្យជនត្រូវចោទលើកបញ្ហាណាមួយ ដែលទាក់ទងនឹងអនិយ័តភាពនៃកិច្ចដំណើរការនីតិវិធីក្នុងការប្រើប្រាស់ភស្តុតាង តាមរយៈនីតិវិធីប្ដឹងមោឃភាពក្នុងដំណាក់កាលស៊ើបអង្កេត និងនីតិវិធីជំទាស់ទៅនឹងការទទួលយកភស្តុតាងនៅក្នុងអំឡុងពេលជំនុំជម្រះលើអង្គសេចក្ដី យោងតាមបទប្បញ្ញត្តិនៃវិធាន៤៨ វិធាន៧៦ និងវិធាន៨៧ នៃវិធានផ្ទៃក្នុង[៣៤]។

៣៥. អនុលោមតាមវិធានទាំងនេះ នៅក្នុងវិធានផ្ទៃក្នុង ភស្តុតាងដែលទទួលបានមិនត្រឹមត្រូវអាចត្រូវបានដកចេញពីសំណុំរឿង នៅពេលមានការរកឃើញថាមានកំហុសនីតិវិធីចំពោះនីតិវិធីនៃការទទួលយក ឬប្រើប្រាស់ភស្តុតាង និងនៅពេលមានការបង្ហាញថា កំហុសនីតិវិធីបែបនោះ ជាការរំលោភបំពានសិទ្ធិទាំងឡាយរបស់ភាគីនៃកិច្ចដំណើរការនីតិវិធី ដែលក្នុងនោះរួមមានជនត្រូវចោទដែរ។

៣៦. វិធាន៧៦(២) នៃវិធានផ្ទៃក្នុងចែងថា ភាគីដែលស្នើសុំមោឃភាពផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវតែដាក់ពាក្យសុំ "ដោយបញ្ជាក់មូលហេតុ"ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីសុំឱ្យសហចៅក្រមស៊ើបអង្កេត ប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ វិធាន៧៦(៤) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចប្រកាសថា ពាក្យសុំមោឃភាពនេះអាចទទួលយកបាន ប្រសិនបើពាក្យសុំបង្ហាញ "ហេតុផលគ្រប់គ្រាន់ក្នុងការប្រកាសមោឃភាព"។ យោងតាមអនុវិធានទាំងនេះ អត្ថិភាពនៃ "ហេតុផលគ្រប់គ្រាន់" គឺជាបុរេលក្ខខណ្ឌ ដើម្បីអាចឱ្យពាក្យសុំនោះទទួលយកបាន និងអាចឱ្យមានចំណាត់ការលើសំណើសុំមោឃភាពនោះ។ ដោយសារតែវិធានផ្ទៃក្នុងពុំបានបកស្រាយអំពីអត្ថន័យនៃ "ហេតុផលគ្រប់គ្រាន់ក្នុងការប្រកាសមោឃភាព" អង្គបុរេជំនុំជម្រះបានពន្យល់ពាក្យនេះយ៉ាងក្បោះក្បាយរួចហើយកាលពីលើកមុន ដោយខ្លួនបានសន្និដ្ឋានថា ភាគីដាក់ពាក្យសុំមោឃភាពមានកាតព្វកិច្ចត្រូវលើកឡើងថា ផ្នែកណាមួយនៃដំណើរការនីតិវិធីត្រូវប្រកាសមោឃៈ ហើយត្រូវផ្ដល់មូលហេតុចំពោះការស្នើសុំមោឃភាពនោះ[៣៥]។

---

[៣៤] ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់ចំពោះបទប្បញ្ញត្តិនៃវិធាន៨៧នៃវិធានផ្ទៃក្នុង សូមអានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩, E43/4 កថាខណ្ឌ ៥-៧។

[៣៥] សាលដីការបស់អ.ប.ជលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, D55/I/8 កថាខណ្ឌ៣២-៤២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៣៧. បន្ថែមលើចំណុចនេះ នៅក្នុងដំណាក់កាលជំនុំជម្រះ ជនត្រូវចោទអាចស្នើសុំឱ្យសួរដេញដោលសាក្សីទាំងឡាយបាន ប្រសិនខ្លួនមានការព្រួយបារម្ភខ្លាំងចំពោះភស្តុតាងជាលាយលក្ខណ៍អក្សរ[៣៦]។ នៅពេលសម្រេចលើភាពអាចទទួលយកបាននៃភស្តុតាងចំពោះមុខខ្លួន អង្គជំនុំជម្រះនីមួយៗមានអំណាចជាប់មកជាមួយធ្វើការស៊ើបអង្កេតបន្ថែម ប្រសិនបើមានបញ្ហាកើតឡើងលើការជំនុំជម្រះដោយយុត្តិធម៌លើផ្នែកណាមួយនៃភស្តុតាង។[៣៧]ម្យ៉ាងវិញទៀត អង្គជំនុំជម្រះតុលាការកំពូលអាចសើរើសាលក្រម ដោយផ្អែកលើមូលហេតុថា "ខ្លួនទើបរកឃើញនាពេលថ្មីៗថា ភស្តុតាងដែលយកមកពិចារណានៅក្នុងដំណាក់កាលជំនុំជម្រះ ហើយដែលយកមកធ្វើជាភស្តុតាងដាក់ទោសនោះ គឺជាភស្តុតាងមានកំហុស មានការប្រឌិតឡើង និងមានការក្លែងបន្លំ"[៣៨]។

៣៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា សហមេធាវីការពារក្តីជនត្រូវចោទ នួន ជាបានស្នើសុំឱ្យព្រះរាជអាជ្ញាអមសាលាដំបូងក្រុងភ្នំពេញស៊ើបអង្កេតលើអំពើពុករលួយដែលបានចោទប្រកាន់។ អង្គបុរេជំនុំជម្រះ មិនច្បាស់ថាតើសំណើនេះធ្វើឡើងដោយផ្អែកលើមូលដ្ឋានអ្វីនោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សំណើសុំនេះត្រូវបានសាលាដំបូងក្រុងភ្នំពេញតម្កល់ទុកឥតចាត់ការ ប៉ុន្តែការបដិសេធលើសំណើនេះបានបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ទៅអគ្គព្រះរាជអាជ្ញា។

៣៩. ជាពិសេស នៅក្នុងករណីនេះ ដោយសារសាលាដំបូងក្រុងភ្នំពេញ ពុំបានផ្តល់សម្អាងហេតុអំពីសេចក្តីសម្រេចរបស់ខ្លួនជូនអង្គបុរេជំនុំជម្រះ ហើយក្នុងពេលបច្ចុប្បន្ននេះ សាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍ ដែលបញ្ហានៃបណ្តឹងឧទ្ធរណ៍នេះ ជាកម្មវត្ថុចម្បងនៃសំណើសុំលើកទីដប់មួយ ដែលលើកឡើងដោយជនត្រូវចោទ យើងពុំអាចសន្និដ្ឋានថា ស្ថាប័នជាតិពុំមានសមត្ថភាព ឬពុំមានភាពអនាគតិ ដែលជាលក្ខខណ្ឌទាមទារចាំបាច់ក្នុងការដោះស្រាយលើបញ្ហានេះឡើយ។

---

[៣៦] សូមអានវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

[៣៧] សូមអានមាត្រា ៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។ *Prosecutor v. Tadic*, IT-94-1-A,"Judgment", 15 July 1999, para. 322; United States of America on Behalf of Lehigh Railroad Company v. Germany, U.S. – German Mixed Claims Commission, reprinted in 34 AM. J.I.L. 151, (1940).

[៣៨] វិធាន ១១២(១)(ខ)នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៤០. អង្គបុរេជំនុំជម្រះយល់ឃើញថា បទដ្ឋានដែលបានចែងនៅក្នុងថ្នាក់អន្តរជាតិដើម្បីបង្ហាញឲ្យឃើញថា ដំណោះស្រាយនៅថ្នាក់ជាតិពុំមានប្រសិទ្ធភាពនោះ មានលក្ខណៈតឹងរ៉ឹងណាស់ ។ ដោយសារតែវិធាន ឬយុត្តិសាស្ត្រទាំងឡាយរបស់តុលាការពិសេស ឬតុលាការព្រហ្មទណ្ឌអន្តរជាតិពុំបានចែងអំពីបទដ្ឋានណែនាំចំពោះបញ្ហានេះ ពីព្រោះតុលាការទាំងនេះមានយុត្តាធិការចម្បងលើយុត្តាធិការជាតិផ្សេងៗគ្នា, យើងអាចយកច្បាប់យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ មកប្រើប្រាស់ជាបទដ្ឋានណែនាំ។

៤១. នៅពេលកំពុងរង់ចាំការដោះស្រាយតាមនីតិវិធីជាតិ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ អាចព្យួរនីតិវិធីនៃការទទួលយកបណ្តឹងសិន ឬក៏ប្រកាសថាបណ្តឹងនោះពុំអាចទទួលយកបានតែម្តង[៣៩]។ ចំពោះបន្ទុកនៃការបង្ហាញភស្តុតាងនៅក្នុងករណីបែបនេះ ប្រសិនបើម្ចាស់បណ្តឹងលើកឡើងថា នីតិវិធីដោះស្រាយណាមួយគ្មានប្រសិទ្ធភាព ឬពុំទទួលបានដំណោះស្រាយ ឬអាចអូសបន្លាយពេលយូរពុំសមហេតុផលនោះ ភាគីត្រូវផ្តល់ភស្តុតាងឱ្យបានច្បាស់លាស់ ដើម្បីគាំទ្រដល់ការចោទប្រកាន់របស់ខ្លួន[៤០]។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានកត់សំគាល់ថា "ប្រសិនបើវាគ្រាន់តែជាមន្ទិលសង្ស័យចំពោះប្រសិទ្ធភាពនៃនីតិវិធីដោះស្រាយតែប៉ុណ្ណោះ ករណីនេះពុំអាចធ្វើឱ្យកាតព្វកិច្ចដោះស្រាយលើរឿងក្តីណាមួយពុំមានប្រសិទ្ធភាពឡើយ" ហើយម្ចាស់បណ្តឹងត្រូវតែដាក់ជូននូវព័ត៌មានឲ្យបានគ្រប់គ្រាន់ ឬព័ត៌មានពាក់ព័ន្ធនឹងករណីចោទប្រកាន់ចំពោះតុលាការដែលពុំបានអនុវត្តនីតិវិធីដោះស្រាយឱ្យមានប្រសិទ្ធភាព ដើម្បីឲ្យគណៈកម្មាធិការធ្វើការពិចារណា និងធ្វើការសេចក្តីសន្និដ្ឋានលើបញ្ហានេះបាន[៤១]។

៤២. អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា សហមេធាវីការពារក្តីជនត្រូវចោទពុំបានផ្តល់នូវព័ត៌មានទាំងឡាយដោយផ្ទាល់ ឬប្រើប្រាស់ព័ត៌មាននោះ នៅក្នុងសំណើលើកទីដប់មួយ ឬក៏នៅក្នុងបណ្តឹងឧទ្ធរណ៍បញ្ជាក់អំពីការអះអាងរបស់ខ្លួនអំពីប្រសិទ្ធិភាព ឬក៏ការបំពេញការងាររបស់ស្ថាប័នក្នុងស្រុក ដែលកំពុងពិនិត្យសំណើរបស់ខ្លួន ឬសំណើរបស់អង្គការសហប្រជាជាតិ។ ការពិត

---

[៣៩] Manfred Nowak, *U.N. Covenant on Civil and Political Rights: CCPR Commentary,* Strasbourg: 1993, p. 704.

[៤០] Manfred Nowak, *U.N. Covenant on Civil and Political Rights: CCPR Commentary,* Strasbourg: 1993, p. 706.

[៤១] *Garcia Perea v. Spain*, Communication No. 1511/2006, "Decision of the Human Rights Committee", 27 March 2009, para. 6.2.



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដែលថា សំណើសុំរបស់ នួន ជា ដែលនឹងត្រូវសម្រេចដោយអគ្គព្រះរាជអាជ្ញា គឺផ្ទុយទៅនឹងការសន្មត់ទាំងនេះ។

៤៣. អង្គបុរេជំនុំជម្រះយល់ឃើញថា អនុលោមតាមវិធានផ្ទៃក្នុង និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា សហមេធាវីការពារក្ដីមានលទ្ធភាពដាក់បណ្ដឹង និងសុំឱ្យដោះស្រាយតាមនីតិវិធីផ្សេងទៀត ដែលការពារយ៉ាងគ្រប់គ្រាន់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ។

៤៤. បន្ថែមលើនេះទៀត អង្គបុរេជំនុំជម្រះកត់សំគាល់ឃើញថា លិខិតុបករណ៍បង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង និងលិខិតុបករណ៍អន្តរជាតិនានា បានធានាដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងឥតលម្អៀង ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋហត្ថលេខី។

៤៥. មាត្រា ១២ នៃកិច្ចព្រមព្រៀងចែងដូចខាងក្រោមនេះ ៖

> "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។ [....]"។

៤៦. មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តម្រូវឱ្យរដ្ឋជាភាគីទាំងអស់បង្កើតតុលាការដែលមានឯករាជ្យ និងមិនលម្អៀង ហើយផ្ដល់ឱ្យតុលាការទាំងនោះនូវរចនាសម្ព័ន្ធនៃស្ថាប័នមួយ និងហិរញ្ញវត្ថុមួយ ដែលអាចឱ្យតុលាការទាំងនោះអនុវត្តការជំនុំជម្រះក្ដីរឿងព្រហ្មទណ្ឌប្រកបដោយយុត្តិធម៌គ្រប់ពេលវេលា និងផ្ដល់ឱ្យគ្រប់ជនជាប់ចោទទាំងអស់នូវសិទ្ធិជាអប្បបរិមាដែលមានធានានៅក្នុងមាត្រា១៤(២)-(៧)[៤២]។

---

[៤២] Manfred Nowak, *U.N. Covenant on Civil and Political Rights: CCPR Commentary*, Strasbourg, 1993, p. 238.



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

៤៧. ចំពោះអនាគិតនៃចៅក្រមរបស់ អ.វ.ត.ក, អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ៣៤ នៃ វិធានផ្ទៃក្នុង ផ្តល់សិទ្ធិឱ្យភាគីនានាលើកឡើងអំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាផល ប្រយោជន៍ជាក់លាក់ ឬភាពលម្អៀងរបស់ចៅក្រម ទៅតាមករណីនីមួយៗ។

៤៨. ពាក់ព័ន្ធនឹងឯករាជ្យភាពរបស់ចៅក្រមរបស់ អ.វ.ត.ក, មាត្រា ៣ នៃកិច្ចព្រមព្រៀង និងមាត្រា ១១ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងយោងលើ បញ្ហានេះ។ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាចែងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអគ្គលេខាធិការអង្គការសហប្រជាជាតិ ជា ស្ថាប័នជ្រើសតាំង និងតែងតាំងចៅក្រមសម្រាប់ អ.វ.ត.ក។ សហមេធាវីការពារក្តីជនត្រូវចោទ បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានទាំងឡាយថា អត្ថិភាពនៃ "ប្រព័ន្ធបង់ប្រាក់សំណូក" អាចធ្វើ ឲ្យប៉ះពាល់ដល់របៀបនៃការតែងតាំងចៅក្រមសម្រាប់ អ.វ.ត.ក ហេតុដូច្នេះ ហើយបង្កើតជា បញ្ហាចោទលើឯករាជ្យភាពរបស់ចៅក្រមពីស្ថាប័នរដ្ឋបាល។ សហមេធាវីការពារក្តីជនត្រូវចោទ លើកទឡ្ហីករណ៍បន្ថែមទៀតថា ប្រសិនបើបុគ្គលិកដែលទទួលភារកិច្ចបំពេញការងាររសើបមាន ឆន្ទៈចូលរួមពាក់ព័ន្ធនៅក្នុងអំពើពុករលួយនោះ នៅពេលនោះបុគ្គលទាំងនោះក៏អាចនឹងមានឆន្ទៈ ដូចគ្នាក្នុងការអនុវត្តន៍តាមសេចក្តីណែនាំដែលមិនសមស្របផងដែរ ហើយវាធ្វើឱ្យប៉ះពាល់ដល់ សេចក្តីសុចរិតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ។

៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់អំពីមន្ត្រីបុគ្គលិកប្រហែលជាបានបង់ប្រាក់ទៅឲ្យ ថ្នាក់លើនោះ មិនអាចនាំឲ្យមានការសន្និដ្ឋានថា មន្ត្រីបុគ្គលិកទាំងនេះអាចមានឥទ្ធិពលបញ្ចុះ បញ្ចូលចៅក្រមឱ្យរៀបចំលទ្ធផលនៃកិច្ចនីតិវិធី ហើយធ្វើឲ្យប៉ះពាល់ដល់ឯករាជ្យភាព និង អនា គតិរបស់តុលាការ ឬក៏ចៅក្រមបានឡើយ។ លក្ខណៈនៃការចោទប្រកាន់បែបនេះ គឺទូលំទូលាយ ពេកមិនអាចឱ្យធ្វើការសន្និដ្ឋានបែបនេះឡើយ លើកលែងតែមានផ្តល់អង្គហេតុបន្ថែមផ្សេងទៀត។

៥០. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនត្រូវចោទដូចមានចែងនៅក្នុងវិធាន ២១នៃវិធានផ្ទៃ ក្នុង ត្រូវបានការពារយ៉ាងពេញលេញដោយក្របខ័ណ្ឌច្បាប់ជាធរមាន ដូចដែលបានផ្តល់សម្អាង ហេតុខាងលើ។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ នៃវិធានផ្ទៃ មិនបានចាប់បង្ខំឲ្យ

00366780

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ២០)

N°: D158/5/3/15

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ៖**

បណ្ដឹងឧទ្ធរណ៍នេះ គឺមិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះ គឺបិទផ្លូវតវ៉ា។ល។

**ភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

**Rowan DOWNING** **ន័យ ធុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**